ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង ៖ ០៥៧/២០ - ស៊ីន ទ្រី (ខេមបូឌា)**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **វ៉ែន ពៅ**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ស៊ីន ទ្រី (ខេមបូឌា)**

អាសយដ្ឋាន ៖ ផ្ទះលេខ៤៤២D សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ៨០ ៩៥ ៥៩ / ០១២ ៥៦ ៧០ ៥៧ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមផ្តល់ព័ត៌មាន ៖

១- លោក ប៉ុល សុភាព អ្នកប្រតិបត្តិធនធានមនុស្ស

២- លោក នៅ ឧត្តម អ្នកប្រតិបត្តិធនធានមនុស្ស

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ស៊ីន ទ្រី (ខេមបូឌា)**

អាសយដ្ឋាន ៖ ផ្ទះលេខ៤៤២D សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០៦៩ ៤៤ ៨៦ ០០ / ០៨៦ ៧៥ ៦៦ ៤២ ទូរសារ ៖ គ្មាន

តំណាងភាគីកម្មករនិយោជិតចូលរួមផ្តល់ព័ត៌មាន ៖ អវត្តមាន

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតស្នើសុំឱ្យក្រុមហ៊ុនទូទាត់ប្រាក់ឈ្នួលខែចុងក្រោយ។

២- កម្មករនិយោជិតស្នើសុំឱ្យក្រុមហ៊ុនទូទាត់ប្រាក់ជួសការជូនដំណឹងមុន។

៣- កម្មករនិយោជិតស្នើសុំឱ្យក្រុមហ៊ុនទូទាត់ប្រាក់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់។

៤- កម្មករនិយោជិតស្នើសុំឱ្យក្រុមហ៊ុនទូទាត់ប្រាក់រំលឹកអតីតភាពការងារមុនឆ្នាំ២០១៩ និងប្រាក់បំណាច់អតីតភាពការងារក្នុងឆ្នាំ២០២០។

៥- កម្មករនិយោជិតស្នើសុំឱ្យក្រុមហ៊ុនទូទាត់ប្រាក់សោហ៊ុយជម្ងឺចិត្ត។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៨៥/២០ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ (អាណត្តិទី១៨)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ស៊ីន ទ្រី(ខេមបូឌា) លេខ ១០៥៨ ក.ប/អក/វក ចុះថ្ងៃព្រហស្បតិ៍ ៦រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២០ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២០។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ។

**កាលបរិច្ឆេទផ្តល់ព័ត៌មាន ៖** ថ្ងៃអង្គារ ១១រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៤ និង ៣០ នាទី រសៀល។

**បញ្ហានីតិវិធី ៖**

នៅថ្ងៃទី៣ ខែតុលា ឆ្នាំ២០២០ នាយកដ្ឋានវិវាទការងារបានទទួលពាក្យបណ្តឹងរបស់កម្មករនិយោជិតនៃក្រុមហ៊ុន ស៊ីនទ្រី (ខេមបូឌា) តាមរយៈទូរសព្ទពីតំណាងកម្មករនិយោជិត ស្តីពីការទាមទារឱ្យនិយោជកផ្តល់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងារជូនកម្មករនិយោជិត ចំនួន ៥ចំណុច។ បន្ទាប់ពីទទួលបណ្តឹងនេះរួចមក នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយវិវាទការងារនេះ ជាបន្តបន្ទាប់ និងបានធ្វើការផ្សះផ្សាវិវាទចំនួន ៥ចំណុចនេះ នៅថ្ងៃទី៥ ខែតុលា ឆ្នាំ២០២០ ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នា។ ចំណុចមិនសះជា ចំនួន ៥ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០២០ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ស៊ីនទ្រី (ខេមបូឌា) លេខ ១០៥៨ ក.ប/អក/វក ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០២០។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី៩ ខែតុលា ឆ្នាំ២០២០ ហើយលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលលិខិតមួយច្បាប់ ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០២០ របស់ក្រុមហ៊ុន ស៊ីនទ្រី (ខេមបូឌា) ដែលមានកម្មវត្ថុស្តីពីសំណើសុំចេញសេចក្តីបញ្ជាដើម្បីផ្អាកការធ្វើកូដកម្មរបស់កម្មករនិយោជិតនៅក្រុមហ៊ុន ស៊ីនទ្រី (ខេមបូឌា)។ ហេតុនេះ នៅថ្ងៃទី៩ ខែតុលា ឆ្នាំ២០២០

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាលេខ ០០៤/២០ កបអ. ឱ្យផ្អាកជាបន្ទាន់នូវការធ្វើកូដកម្មរបស់កម្មករនិយោជិតនៃក្រុមហ៊ុន ស៊ីនទ្រី (ខេមបូឌា) រហូតដល់នីតិវិធីនៃអាជ្ញាកណ្តាលត្រូវបានបញ្ចប់សព្វគ្រប់ តាមនីតិវិធីច្បាប់ ហើយកូដករទាំងអស់ត្រូវត្រឡប់ចូលធ្វើការវិញ ចាប់ពីរសៀលថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ តទៅតាមវេនរបស់ខ្លួន។

បន្ទាប់ពីចេញសេចក្តីបញ្ជានេះមក នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៩ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលដំណឹងពីភាគីនិយោជក និងកម្មករនិយោជិត តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលថា កម្មករនិយោជិតមិនបានត្រឡប់ចូលធ្វើការតាមសេចក្តីបញ្ជានោះទេ ហើយនៅតែបន្តធ្វើកូដកម្មដដែល។ នៅក្នុងលិខិតជូនដំណឹងមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ ភាគីកម្មករនិយោជិតបានបញ្ជាក់ថា មានកម្មករនិយោជិតមួយចំនួននៅបន្តធ្វើកូដកម្ម។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញភាគីពាក់ព័ន្ធមកសាកសួរព័ត៌មានបន្ថែម ក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាលនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៤ និង ៣០ នាទី រសៀល។ នៅក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាល ភាគីនិយោជកមានវត្តមានតាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយឡែកភាគីកម្មករនិយោជិតបានអវត្តមាននៅក្នុងកិច្ចប្រជុំនេះ។ នៅក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាល ភាគីនិយោជកបានបញ្ជាក់ថា មកដល់ពេលបច្ចុប្បន្ននេះ មានកម្មករនិយោជិតប្រមាណ ១០ភាគរយ ដែលបានត្រឡប់ចូលធ្វើការវិញ ក្នុងចំណោមកម្មករនិយោជិតសរុប ចំនួន ១៩១២នាក់ ឯកម្មករនិយោជិតដទៃទៀត នៅបន្តធ្វើកូដកម្មដដែល។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណា ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

### ក- ឯកសារបានទទួលពីភាគីនិយោជក

១- លិខិតផ្ទេរសិទ្ធិ លេខ ០២២៨/២០ ស.ទ.ខ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ របស់លោក សេង សូរីដា ជាអនុប្រធានក្រុមហ៊ុន ស៊ីន ទ្រី(ខេមបូឌា) ផ្ទេរសិទ្ធិជូន លោក ប៉ុល សុភាព និងលោក នៅ ឧត្តម តួនាទីជាអ្នកប្រតិបត្តិធនធានមនុស្ស ឱ្យធ្វើជាអ្នកតំណាងឱ្យក្រុមហ៊ុន ក្នុងការចូលរួមផ្តល់ព័ត៌មានក្នុងសំណុំរឿងលេខ ០៥៧/២០ នៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ។

២- លិខិតចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ របស់លោក ហេង ឌីម៉ង់ តំណាងបុគ្គលិក-កម្មករ គោរពជូន លោកប្រធានក្រុមហ៊ុន ស៊ីន ទ្រី (ខេមបូឌា) ស្តីពីសំណើសុំក្រុមហ៊ុន ស៊ីន ទ្រី(ខេមបូឌា) ទូទាត់បញ្ចប់កិច្ចសន្យាការងារដល់កម្មករនិយោជិតដែលកំពុងបម្រើការងារ។

៣- លិខិតចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០ របស់លោក កៅ សុវ៉ាត ប្រធានសហជីព គោរពជូន លោកប្រធានក្រុមហ៊ុន ស៊ីន ទ្រី (ខេមបូឌា) ស្តីពីសំណើសុំក្រុមហ៊ុន ស៊ីន ទ្រី(ខេមបូឌា) ទូទាត់បញ្ចប់កិច្ចសន្យាការងារដល់កម្មករនិយោជិតដែលកំពុងបម្រើការងារ។

៤- កំណត់ហេតុស្តីពីការសម្របសម្រួលដោះស្រាយករណីកូដកម្ម របស់កម្មករក្រុមហ៊ុន ស៊ីន ទ្រី(ខេម-បូឌា) ចុះថ្ងៃពុធ ៥រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០៧ ខែតុលា ឆ្នាំ ២០២០។

THE ARBITRATION COUNCIL

៥- លិខិតចុះថ្ងៃសុក្រ ៧រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០៩ ខែតុលា ឆ្នាំ ២០២០ របស់លោក ប៉ុល សុភាព និងលោក នៅ ឧត្តម ជាតំណាងភាគីក្រុមហ៊ុន ស៊ីន ទ្រី(ខេមបូឌា) គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំចេញសេចក្តីបញ្ជាដើម្បីផ្អាកការធ្វើកូដកម្ម ។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- លិខិតជូនដំណឹង ចុះថ្ងៃចន្ទ ១០រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ របស់តំណាងភាគីកម្មករនិយោជិតក្រុមហ៊ុន ស៊ីន ទ្រី(ខេមបូឌា) គោរពជូន លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីការជូនដំណឹងអំពីការមិនចូលរួមសវនាការនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ស៊ីន ទ្រី(ខេមបូឌា) លេខ ១០៥៨ ក.ប/អក/វក ចុះថ្ងៃព្រហស្បតិ៍ ៦រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២០។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ស៊ីន ទ្រី(ខេមបូឌា) ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ស៊ីន ទ្រី(ខេមបូឌា) លេខ ០១០ កប/អក/វក/កវក៤ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២០ របស់នាយកដ្ឋានវិវាទការងារ។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតលេខ ៣៥៣ កប/អក/វក/លកអ. ចុះថ្ងៃសុក្រ ៧រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព. ស ២៥៦៤ ត្រូវនឹងថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០ របស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ជម្រាបមក លោក-លោកស្រីតំណាងភាគីម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៅក្រុមហ៊ុន ស៊ីន ទ្រី(ខេមបូឌា) ស្តីពីការជ្រើសរើសអាជ្ញាកណ្តាល។

២- កំណត់ហេតុ ស្តីពីការចាប់ឆ្នោតជ្រើសរើសអាជ្ញាកណ្តាលពីបញ្ជីឈ្មោះអាជ្ញាកណ្តាល ស្នើដោយសហជីព កម្មករនិយោជិត នៃក្រុមហ៊ុន ស៊ីន ទ្រី(ខេមបូឌា) ចុះថ្ងៃសុក្រ ៧រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០។

៣- សេចក្តីបញ្ជា លេខ ០០៤/២០ កបអ. ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០ របស់ក្រុមប្រឹក្សាអាជ្ញា-កណ្តាល។

៤- លិខិតអញ្ជើញភាគីនិយោជកចូលរួមផ្តល់ព័ត៌មាន លេខ ៣៥៤ កប/អក/វក/លកអ. ចុះថ្ងៃចន្ទ១០រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០។

៥- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមផ្តល់ព័ត៌មាន លេខ ៣៥៥កប/អក/វក/លកអ. ចុះថ្ងៃចន្ទ ១០រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០។

**អង្គហេតុ**

មិនមានការរកឃើញអង្គហេតុ ទាក់ទងទៅនឹងចំណុចបញ្ហាវិវាទនៅក្នុងរបាយការណ៍មិនសះជា ដែលនាយកដ្ឋានវិវាទការងារបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ដោយសារក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនបានដំណើរការសវនាការ។

## ហេតុផលនៃសេចក្តីសម្រេច៖

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើត្រូវបន្តនីតិវិធីអាជ្ញាកណ្តាលដែរ ឬទេ?

ប្រការ ២០ នៃប្រកាសលេខ ០៩៩ សកបយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចែងថា៖ *"ក្នុងអំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ភាគីវិវាទទាំងឡាយត្រូវផ្អាករាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ (ដូចមានចែងក្នុងមាត្រា ៣១៨ នៃច្បាប់ស្តីពីការងារ) ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ។ ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយ ដែលក្រុមអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម"*។

យោងតាមប្រការ ២០ នៃប្រកាសលេខ ០៩៩ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីវិវាទត្រូវផ្អាករាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ នៅក្នុងដំណើការអាជ្ញាកណ្តាល។

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយប្រការនេះថា ក្រុមប្រឹក្សាអាជ្ញាកណ្តាល មិនបន្តដំណើរការអាជ្ញាកណ្តាលទេ នៅពេលណាកម្មករនិយោជិតកំពុងធ្វើកូដកម្ម ឬនិយោជកកំពុងធ្វើឡុកអៅ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៥៩/០៦-សាង រ៉ូ, លេខ ៣៩/០៨-ចុងយ៉ូវ, លេខ ១៣៧/០៩ &១៣៨/០៩-ញ៉ូ កាញ់, លេខ ១១០/១១-ស៊ីម៉ាណូ, លេខ ១០៤/១៣-សាប្រ៊ីណា (ខេមបូឌា), លេខ ៣២២/១៤-ជីមលី (ខេមបូឌា) ភីធីអុី អិលធីឌី, លេខ ០៧១/១៥-អ៊ឹម រ៉េ កាត់ដេរ អន្តរជាតិ សាខាកំពង់ឆ្នាំង និងលេខ ០២១/១៦-ស្តារឡៃច៍ អីកែរើល មេនូហ្វេកធឺរីង)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

នៅក្នុងសំណុំរឿងនេះ នៅក្នុងនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភាគីកម្មករនិយោជិតបាននិងកំពុងតែធ្វើកូដកម្ម ហើយក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលសំណើពីតំណាងនិយោជក ស្នើសុំឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលចេញសេចក្តីបញ្ជា ដើម្បីផ្អាកការធ្វើកូដកម្មរបស់កម្មករនិយោជិត។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាលេខ ០០៤/២០ កបអ. ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០២០ ឱ្យកម្មករនិយោជិតបញ្ឈប់កូដកម្ម និងចូលធ្វើការធម្មតា និងបានអញ្ជើញភាគីទាំងពីរមកចូលរួមកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាល នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ ដើម្បីសួរបញ្ជាក់ពីករណីកូដកម្មនេះ។ នៅក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាល ភាគីកម្មករនិយោជិតបានអវត្តមាន ហើយភាគីនិយោជកបានលើកឡើងថា មកដល់ថ្ងៃនេះ កម្មករនិយោជិតនៅតែបន្តធ្វើកូដកម្មដដែល។ ករណីនេះ ភាគីនិយោជកបានបញ្ជាក់បន្ថែមថា មកដល់ពេលបច្ចុប្បន្ននេះ មានតែកម្មករនិយោជិត ចំនួន ប្រមាណ ១០ភាគរយប៉ុណ្ណោះ ដែលបានត្រឡប់ចូលធ្វើការវិញ ក្នុងចំណោមកម្មករនិយោជិតសរុប ចំនួន ១៩១២នាក់។

ហេតុនេះ យោងតាមប្រការ ២០ នៃប្រកាសលេខ ០៩៩ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បញ្ចប់ដំណើរការអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ។

យោងតាមអង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

## សម្រេច

- បញ្ចប់ដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ ០៥៧/២០-ស៊ីនទ្រី (ខេមបូឌា)។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖**

ឈ្មោះ ៖ **អ៊ុំខ សុទ្ធី**

ហត្ថលេខា ៖ ------------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖**

ឈ្មោះ ៖ **ម៉ែន ពៅ**

ហត្ថលេខា ៖------------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល ៖**

ឈ្មោះ ៖ **ម៉ែន ម៉ុនឈា**

ហត្ថលេខា ៖ ------------------------------